health.nsw.gov.au

# ទឹកដោះអ្នកបរិច្ចាគដែលបានកម្តៅរម្ងាប់មេរោគ សម្រាប់ទារកដែលងាយឈឺចាប់

**Pasteurised Donor Human Milk for Vulnerable Babies**

**Khmer**

## NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល) និង Australian Red Cross Lifeblood Service (សេវាកម្មផ្គត់ផ្គង់ឈាមចាំបាច់ចំពោះជីវិត កាកបាទក្រហមអូស្ត្រាលី) កំពុងធ្វើការរួមគ្នា ដើម្បីផ្តល់ឱ្យទារកដែលងាយឈឺចាប់ក្នុងរដ្ឋញូវសៅវែល នូវអាហារជំនួសដែលល្អបំផុត និងមានសុវត្ថិភាពបំផុត ប្រសិនបើមិនអាចរកបានទឹកដោះម្តាយផ្ទាល់។

ទឹកដោះអ្នកបរិច្ចាគដែលបានកម្តៅរម្ងាប់មេរោគ (PDHM) គឺជាទឹកដោះដ៏មានតម្លៃ ហើយត្រូវបានយកប្រើសម្រាប់តែទារកតូចជាងគេ ឬឈឺបំផុតប៉ុណ្ណោះ ដែលអាចទទួលបានអត្ថប្រយោជន៍ដ៏ច្រើនបំផុត។ នេះរួមមានទារកកើតមិនគ្រប់ខែ មានបញ្ហាពោះវៀន ឬបេះដូង ឬបញ្ហាធ្ងន់ធ្ងរផ្សេងទៀត។

ទឹកដោះម្តាយផ្ទាល់ គឺជាអាហារបំប៉នដ៏ល្អបំផុត សម្រាប់ទារកងាយឈឺចាប់។ ម្តាយខ្លះអាចមានការពិបាកក្នុងការផលិតទឹកដោះឱ្យបានគ្រប់គ្រាន់ នៅដើមសប្តាហ៍ដំបូងនៅពេលទារករបស់ពួកគេស្ថិតក្នុង Neonatal Intensive Care Unit (បន្ទប់សង្គ្រោះបន្ទាន់សម្រាប់កូនខ្ចី) (NICU)។ ប្រសិនបើការនេះកើតឡើង ហើយកូនរបស់អ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យ ពួកគេនឹងមានសិទ្ធិទទួលបាន ទឹកដោះអ្នកបរិច្ចាគដែលបានកម្តៅរម្ងាប់មេរោគ។

## អត្ថប្រយោជន៍នៃទឹកដោះម្តាយ ទល់នឹងម្សៅទឹកដោះគោ

ទឹកដោះម្តាយគឺជាអាហារបំប៉នដ៏ល្អបំផុត សម្រាប់ទ្រទ្រង់កូនរបស់អ្នក ពីព្រោះ៖

- វាងាយរំលាយជាងម្សៅទឹកដោះគោ
- វាគ្របបាំងជាស្រទាប់ និងការពារពោះវៀន ហើយបន្ថយហានិភ័យ ឬភាពធ្ងន់ធ្ងរនៃជំងឺពោះវៀនធ្ងន់ធ្ងរ ដែលគេហៅថា Necrotising Enterocolitis (ការស្លាប់ជាលិកាពោះវៀនធំ និងពោះវៀនតូច) (NEC)
- វាផ្តល់នូវការការពារប្រឆាំងនឹងការឆ្លងមេរោគធ្ងន់ធ្ងរមួយចំនួន
- មានអ្វីៗជាច្រើននៅក្នុងទឹកដោះម្តាយ ដែលមិនអាចផលិតជាម្សៅទឹកដោះ
- វាផ្តល់នូវការលូតលាស់ល្អបំផុត និងការអភិវឌ្ឍខួរក្បាលរយៈពេលវែងរបស់កូនអ្នក។

**ទឹកដោះម្តាយ គឺល្អបំផុតសម្រាប់ទារក។**

## សំណួរដែលគេសួរជាញឹកញាប់

### តើកូនរបស់ខ្ញុំអាចបំបៅ ទឹកដោះអ្នកបរិច្ចាគដែលបានកម្តៅរម្ងាប់មេរោគ រយៈពេលយូរប៉ុន្មាន?

ទឹកដោះអ្នកបរិច្ចាគដែលបានកម្តៅរម្ងាប់មេរោគ ត្រូវបានបញ្ជាដោយវេជ្ជបណ្ឌិតរបស់កូនអ្នក ខណៈពេលដែលកូនរបស់អ្នកមានសិទ្ធិទទួលបានវា។ ពេលណាការផ្គត់ផ្គង់ទឹកដោះផ្ទាល់ខ្លួនរបស់អ្នក កំពុងបំពេញតាមសេចក្តីត្រូវការកូនរបស់អ្នកហើយ ទឹកដោះអ្នកបរិច្ចាគនឹងមិនត្រូវការទៀតទេ។ ទោះយ៉ាងណាក្តី ប្រសិនបើទឹកដោះរបស់អ្នក មិនអាចគ្រប់សម្រាប់សេចក្តីត្រូវការទេ កូនរបស់អ្នកនឹងផ្លាស់ប្តូរទៅម្សៅទឹកដោះគោនៅប្រហែលជា 34 សប្តាហ៍ ប្រសិនបើពួកគេលែងមានហានិភ័យខ្ពស់ទៀតហើយ។

### តើនឹងមានទឹកដោះអ្នកបរិច្ចាគដែលបានកម្តៅរម្ងាប់មេរោគគ្រប់គ្រាន់ សម្រាប់ទារកទាំងអស់ដែលត្រូវការវាទេ?

ពេលខ្លះ ទារកត្រូវការទឹកដោះអ្នកបរិច្ចាគ ច្រើនជាងដែលអាចរកបាន។ ប្រសិនបើរឿងនេះកើតឡើង ទឹកដោះអ្នកបរិច្ចាគនឹងត្រូវផ្តល់ឱ្យទារកដែលតូចជាងគេ និងឈឺបំផុត។ អ្នកនឹងត្រូវបានគេប្រាប់ ប្រសិនបើរឿងនេះប៉ះពាល់ដល់ការផ្គត់ផ្គង់សម្រាប់កូនរបស់អ្នក។

### តើការកម្តៅរម្ងាប់មេរោគផ្លាស់ប្តូរទឹកដោះម្តាយទេ?

ទឹកដោះផ្ទាល់ខ្លួនរបស់អ្នក ត្រូវបានផលិតជាពិសេសសម្រាប់កូនរបស់អ្នក។ នៅពេលយើងកម្តៅរម្ងាប់មេរោគទឹកដោះអ្នកបរិច្ចាគ ដើម្បីធ្វើឱ្យវាមានសុវត្ថិភាព មានសារជាតិខ្លះត្រូវបានបាត់បង់។ វានៅតែមានកត្តាជាច្រើន ដែលជួយការពារកូនរបស់អ្នក ដែលមិនមាននៅក្នុងម្សៅទឹកដោះគោ។

### តើអ្នកណាបរិច្ចាគទឹកដោះម្តាយ?

ទឹកដោះអ្នកបរិច្ចាគ គឺជាអំណោយដ៏សប្បុរសពីម្តាយម្នាក់ទៅម្តាយម្នាក់ទៀត។ ពួកគេប្រហែលជាកំពុងបំបៅកូនរបស់ពួកគេផ្ទាល់ ហើយមានទឹកដោះលើសពីតម្រូវការ ឬមានទឹកដោះកកដែលពួកគេបានច្របាច់ទុក សម្រាប់កូនរបស់ពួកគេនៅក្នុង NICU ដែលបន្ទាប់មក ត្រូវបានចាកចេញពីទីកន្លែងនោះ។ បន្ទាប់ពីការបាត់បង់កូន ម្តាយអាចបន្តច្របាច់ទឹកដោះ ជាវិធីសម្តែងនូវការគោរពចងចាំកូនរបស់ពួកគេ និងផ្តល់ឱ្យទារកផ្សេងទៀតនូវឱកាសល្អបំផុត សម្រាប់ជីវិតដែលមានសុខភាពល្អ។

### តើទឹកដោះអ្នកបរិច្ចាគមានសុវត្ថិភាពប៉ុណ្ណាដែរ?

ស្ត្រីមានសិទ្ធិបរិច្ចាគទឹកដោះប៉ុណ្ណោះ បន្ទាប់ពីការធ្វើសម្ភាសន៍ និងការធ្វើតេស្តឈាមដើម្បីធ្វើឱ្យប្រាកដថា ទឹកដោះរបស់ពួកគេមានសុវត្ថិភាព។ ស្វែងយល់ពីដំណើរការបរិច្ចាគ នៅតាមគេហទំព័រ https://www.lifeblood.com.au/milk។

ទឹកដោះអ្នកបរិច្ចាគ ត្រូវបានគេយកទៅកម្តៅរម្ងាប់មេរោគ ដើម្បីសម្លាប់បាក់តេរី និងវីរុសដែលបង្កគ្រោះថ្នាក់។ ហានិភ័យនៃការឆ្លងមេរោគ ទោះជាតិចតួចយ៉ាងណាក្តី ក៏មិនអាចកាត់បន្ថយដល់សូន្យបានទេ។ Australian Red Cross Lifeblood Service Milk Bank (ធនាគារទឹកដោះរបស់ សេវាកម្មផ្គត់ផ្គង់ឈាមចាំបាច់ចំពោះជីវិត កាកបាទក្រហមអូស្ត្រាលី) អនុលោមតាមគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងការឆ្លងរបស់ NSW Health (ក្រសួងសុខាភិបាល រដ្ឋញូវសៅវែ) និង NSW Food Authority (និងអាជ្ញាធរស្បៀងអាហារ រដ្ឋញូវសៅវែល)។ នៅក្នុងទសវត្សនៃធនាគារកិច្ចទឹកដោះមនុស្ស នៅទូទាំងពិភពលោក ពុំមានរបាយការណ៍ដែលបានចេញផ្សាយ អំពីជំងឺឆ្លងដែលបណ្តាលមកពី ទឹកដោះអ្នកបរិច្ចាគដែលបានកម្តៅរម្ងាប់មេរោគទេ។

### តើម្តាយត្រូវបានគេបង់ប្រាក់នៅពេលពួកគេបរិច្ចាគទឹកដោះឬទេ?

ទេ។ ម្តាយមិនត្រូវបានគេបង់ប្រាក់ ដើម្បីបរិច្ចាគទឹកដោះទេ។

### តើខ្ញុំអាចដឹងថា អ្នកណាបានផ្តល់ទឹកដោះសម្រាប់កូនរបស់ខ្ញុំទេ?

ទេ។ យើងរក្សាការសម្ងាត់យ៉ាងតឹងរ៉ឹង ទាំងអ្នកបរិច្ចាគ និងអ្នកទទួលទឹកដោះ។ នេះគឺជាគោលការណ៍របស់យើង។

December 2021 © NSW Health. SHPN (HSP) 211159-7.